# ធម្មទេសនារបស់លោកអភិបាល អូលីវីយេ
# អភិបូជាសិក្ខាសាលាយុវជន
# ចំការទៀង ថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០១៩
# ឲ្យយើងរស់នៅជាគ្រួសាររួមយរឹងមាំ

**អត្ថបទទី១៖ យេរេមី ១៧,៥-៨**

រីឯអ្នកដែលផ្ញើជីវិតលើព្រះអម្ចាស់ និងយកព្រះអង្គធ្វើជាបង្អែក ពិតជាទទួលព្រះពរមិនខាន! ។ យរ ១៧,៧

**អត្ថបទទី២៖ កូរិនថូសទី១ ១៥,១២.១៦-២០**

ហើយបើព្រះគ្រីស្តមិនបានរស់ឡើងវិញទេ ជំនឿរបស់បងប្អូនគ្មានន័យអ្វីទាល់តែសោះ បងប្អូននៅតែជាប់បាបដដែល។ ១ករ ១៥,១៧

**ដំណឹងល្អ៖ លូកា ៦,១៧.២០-២៦**

ប្រសិនបើមានគេស្អប់លែងរាប់រកអ្នករាល់គ្នា ប្រសិនបើគេត្មះតិះដៀលបង្ខូចឈ្មោះអ្នករាល់គ្នាព្រោះតែបុត្រមនុស្ស អ្នករាល់គ្នាមានសុភមង្គលហើយ។ លក ៦,២២

បងប្អូនជាទីស្រឡាញ់!

ថ្ងៃនេះព្រះយេស៊ូមានព្រះបន្ទូលថា "**ប្រសិនបើយើងរស់នៅជាអ្នកក្រខ្សត់មានសុភមង្គលហើយ ប្រសិនបើយើងយំមានសុភមង្គលហើយ ប្រសិនបើយើងឃ្លានមានសុភមង្គលហើយ ផ្ទុយទៅវិញអ្នកមាននឹងត្រូវវេទនាមិនខាន អ្នកសើចនឹងត្រូវវេទនាមិនខាន អ្នកញ៉ាំឆ្អែតនឹងត្រូវវេទនាមិនខាន**"។ បន្តិចទៀតបងស្រីម៉ារីអង់ គាត់ធ្វើពាក្យសច្ចារបស់គាត់ផ្ញើជីវិតទៅលើព្រះជាម្ចាស់ដោយសុខចិត្តរស់នៅជាអ្នកក្រខ្សត់។ ក្នុងអត្ថបទទី១ "**ព្រះជាម្ចាស់មានព្រះបន្ទូលថា ប្រសិនបើយើងផ្ញើជីវិតទៅលើព្រះជាម្ចាស់ ប្រសិនបើយើងយកព្រះអង្គធ្វើជាបង្អែក ពិតមែនយើងទទួលព្រះពរជាមិនខាន និងណែនាំឲ្យយើងប្រៀបបីដូចជាដើមឈើដុះនៅក្បែរផ្លូវទឹក ដែលមានឫសចាក់ទៅរកទឹកហូរ វាមិនខ្លាចកម្តៅហើយស្លឹករបស់វានៅខៀវខ្ចីជានិច្ច**"។ ពេលយើងស្តាប់នេះយើងសប្បាយចិត្តហើយ ដោយសារយើងដឹងថាប្រសិនបើយើងភ្ជាប់ជាមួយព្រះជាម្ចាស់ ជីវិតរបស់យើងបីដូចជាដើមឈើមួយយ៉ាងធំ ដែលចាក់ឫសរហូតដល់ទឹកដើម្បីឲ្យមានជីវិតពេញមួយឆ្នាំស្លឹកខៀវខ្ចីពេញមួយឆ្នាំ ក្តៅក៏ដោយ ស្ងួតក៏ដោយ រាំងក៏ដោយ ទុរគតក៏ដោយ កុំព្រួយបារម្ភ។

នេះ ជាអ្វីដែលព្រះជាម្ចាស់ចង់និយាយ ឲ្យជីវិតរបស់យើងពឹងផ្អែកទៅលើព្រះជាម្ចាស់ ឲ្យជីវិតរបស់យើងដូចដើមឈើមួយយ៉ាងពិសេស ដែលមានស្លឹកខៀវខ្ចីជានិច្ច ដែលមិនខ្លាចរដូវប្រាំង ដែលមិនខ្លាចរដូវភ្លៀង ដោយដឹងថាមានជីវិតជានិច្ច ដោយសារយើងមានព្រះជាម្ចាស់ជាទីពឹងមួយយ៉ាងពិសេស។ ឲ្យយើងធ្វើជាមនុស្សរឹងមាំដូចដើមឈើ មានន័យថាឲ្យជីវិតរបស់យើង

ទៅជាជីវិតស្អាត ឲ្យជីវិតរបស់យើងទៅជាជីវិតពិសេស។ ជីវិតរបស់ទៅជាជីវិតស្អាតនិងពិសេស លុះត្រាតែយើងចេះយំ គឺមិនយំដោយសារយើងឈឺចិត្តឈ្លោះគ្នា យំដោយសារយើងចេះមើលឃើញទុក្ខលំបាករបស់បងប្អូនឯទៀៗ។ នៅពេលយើងឃើញបងប្អូនឯទៀតៗដែលពិបាកចិត្ត ឈឺ ខ្វះខាត ទៅរៀនមិនបាន អត់មានផ្ទះ អត់មានកន្លែងនៅ ឲ្យយើងឈឺចិត្តទៅ ឲ្យយើងយំដោយថែរក្សាចិត្តអាណិតមេត្តា ជាអ្វីដែលព្រះយេស៊ូចង់ឲ្យយើងមាន។ ម្យ៉ាងទៀត ឲ្យយើងចេះយំពេលយើងឃើញផ្ទាល់ខ្លួន ដោយសារជីវិតរបស់យើងជួនកាលជាប់នឹងអំពើបាប ជាប់នឹងអំពើខុស ពេលយើងធ្វើបាបគេ ពេលយើងវៃគេ ពេលយើងនិយាយដើមគេ ពេលយើងមើលងាយគេ ឲ្យយើងយំផ្ទាល់ខ្លួនដែរ ដោយសារយើងដឹងថាថ្ងៃនេះខ្ញុំធ្វើអ្វីដែលអត់ល្អទេ ថ្ងៃនេះខ្ញុំដើរតាមផ្លូវអាក្រក់ ថ្ងៃនេះខ្ញុំធ្វើអំពើបាប។ នេះជាមូលហេតុ ព្រះយេស៊ូចង់ឲ្យយើងយំដោយមានសុភមង្គល ដោយសារបើយើងចេះតែសើចយើងភ្លេចមើលឃើញគេ យើងសើចដោយសារគេជាអ្នកសុំទានតាមផ្លូវ យើងសើចដោយសារគេអត់មានលុយទិញម៉ូតូស្អាតៗ យើងមើលងាយគេ ព្រះយេស៊ូមិនចង់ឲ្យយើងធ្វើរបៀបនេះទេ។

ព្រះយេស៊ូចង់ឲ្យយើងយំ ដោយមានចិត្តអាណិតមេត្តា ចិត្តស្រឡាញ់ដល់បងប្អូនឯទៀតៗ ព្រះយេស៊ូណែនាំឲ្យយើងឃ្លានសេចក្តីស្រឡាញ់ដែលមកពីព្រះជាម្ចាស់ ឲ្យយើងឃ្លានសេចក្តីស្រឡាញ់ដែលយើងត្រូវការប្រគល់ឲ្យបងប្អូនឯទៀតៗ។ ប្រសិនបើយើងឆ្អែត យើងអត់មានកន្លែងដែលគិតដល់ព្រះជាម្ចាស់ទេ ពេលយើងឆ្អែតពេកយើងងងុយដេក។ ផ្ទុយទៅវិញឲ្យយើងមានកន្លែង ដើម្បីស្តាប់ព្រះបន្ទូលរបស់ព្រះជាម្ចាស់ ដូចយើងបានមកជួបជុំគ្នាពីម្សិលមិញនិងថ្ងៃនេះ ដើម្បីទទួលការអប់រំ ដើម្បីស្តាប់ព្រះបន្ទូល ដើម្បីបង្កើតមិត្តភក្តិថ្មីៗ ដើម្បីអធិដ្ឋាន ដើម្បីរស់នៅក្នុងគ្រួសារមួយធំដែលជាគ្រួសាររបស់ព្រះសហគមន៍ ដោយសារយើងអត់ទាន់ឆ្អែតដូច្នេះ យើងបានទៀត ចង់ស្តាប់ទៀត យើងចង់ស្គាល់ទៀត ដូច្នេះអ្នកដែលឃ្លានមានសុភមង្គលហើយ។

ព្រះយេស៊ូមិនចង់ឲ្យយើងទៅជា អ្នកក្រីក្រដែលអត់មានលុយទៅមន្ទីរពេទ្យ អ្នកក្រីក្រដែលអត់មានលុយដើម្បីទៅសាលា អ្នកក្រីក្រដែលអត់មានលុយដើម្បីធ្វើផ្ទះ ព្រះយេស៊ូចង់ឲ្យយើងមានគំនិតមួយ ដាក់ខ្លួន កុំយើងពោរពេញដោយអាត្មាភាពខ្លាំងពេក កុំឲ្យយើងពោរពេញអាត្មានិយមខ្លាំងពេក ធ្វើឲ្យយើងលែងចេះមើលអ្នកដទៃ។ តាមពិតកូនសោនៃទ្វារស្ថានបរមសុខកូនសោដើម្បីរស់នៅជាគ្រីស្តបរិស័ទពិតៗ គឺដាក់ចិត្តជាអ្នកក្រខ្សត់។ ពេលយើងដាក់ខ្លួនហើយយើងឃ្លានបាន ពេលយើងដាក់ខ្លួនហើយយើងយំបាន ពេលនោះយើងមានសុភមង្គល។ ដូច្នេះយើងគិតថ្ងៃនេះធ្វើយ៉ាងម៉េចទីពឹងលើព្រះជាម្ចាស់ ដោយយើងដឹងថានៅពេលយើងទីពឹងលើព្រះ

ជាម្ចាស់ ជីវិតរបស់យើងប្រៀបដូចជាដើមឈើមួយដែលចាក់ឫសយ៉ាងជ្រៅរហូតដល់ទឹក ដើម្បីឲ្យមានស្លឹកខៀវខ្ចីជានិច្ច ដើម្បីមានផ្លែស្អាតៗជានិច្ច ដើម្បីមានកម្លាំងនិងមែកវែងៗ ដែលណែនាំឲ្យគ្រប់បក្សាបក្សីអាចធ្វើសំបុកបាន នេះគឺសេចក្ដីសុខរបស់ព្រះសហគមន៍។ យើងម្នាក់ៗ យើងជាដើមឈើមួយយ៉ាងតូចដែលចាក់ឫសយ៉ាងជ្រៅ ពេលយើងសរុបដើមឈើនេះទាំងអស់ព្រះសហគមន៍ទៅជាព្រៃមួយយ៉ាងធំ ដែលមានម្លប់ ដែលមានសត្វគ្រប់ប្រភេទ ដែលសប្បាយចិត្តរស់នៅជាមួយគ្នាយ៉ាងមានសេចក្ដីសុខ តោអាចនៅជាមួយពពែបាន ឆ្កែនៅជាមួយឆ្មាបាន កណ្ដុរនៅជាមួយឆ្មាបាន នេះជារបៀបរបស់ព្រះសហគមន៍។

គ្រួសារមួយដែលរស់នៅជាមួយគ្នាបាន អង្គុយជាមួយគ្នាបាន នៅក្នុងព្រៃឈើមួយយ៉ាងស្អាត។ យើងត្រូវនឹកឃើញនេះ ឲ្យយើងទៅជាមនុស្សរឹងមាំ ឲ្យយើងទៅជាដើមឈើមួយយ៉ាងរឹងមាំដែលមានស្លឹកខៀវខ្ចី ដែលមានផ្លែយ៉ាងច្រើន មានន័យថា ចេះស្រឡាញ់ អាណិតមេត្តា រស់នៅក្នុងសេចក្ដីសុខ ដើម្បីណែនាំឲ្យបងប្អូនយើងទោះបីយើងមានគំនិតខុសគ្នាប៉ុន្តែរស់នៅក្នុងព្រះសហគមន៍បាន ដោយសារយើងជាគ្រួសារមួយដែលចេះគោរពគ្នាទៅវិញទៅមក។ យើងអរគុណព្រះជាម្ចាស់ សូមព្រះអង្គប្រទានពរឲ្យយើងមានកម្លាំងកាយកម្លាំងចិត្ត ដើម្បីរស់នៅជាគ្រួសារមួយរឹងមាំដ៏សុខសាន្ត។ អាម៉ែន៕